# ករណីសិក្សាអំពីភាពបំរែបំរួលគ្រួសារកសិករបន្ទាប់ពីការសហការជាមួយគំរោង
# ខែ ធ្នូ ឆ្នាំ ២០០៨

***By Mr. Bao Vuthy***

លោកពូ អ៊ុក ភឿន ជាកសិករសហការម្នាក់របស់ សេដាក មានអាយុ ៥៨ ឆ្នាំ រស់នៅភូមិស្រីជ័យ ឃុំបឹងត្រាញ់ត្បូង ស្រុកសំរោង ខេត្តតាកែវ។ គាត់ជាមេគ្រួសារដែលមានសមាជិកនៅក្នុងបន្ទុកចំនួន ៥ នាក់ (កូនប្រុស ៣នាក់ និង ប្តីប្រពន្ធ ២នាក់) ហើយគាត់មានផ្ទៃដីដាំដុះសរុបចំនួន ២.៥ ហ.ត ក្នុងនោះដីធ្វើស្រែមាន ២ ហ.ត និងដីចំការ ០.៥ ហ.ត។ តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ លោកពូរស់នៅតែពីរនាក់ ប្រពន្ធ-ប្តីប៉ុណ្ណោះ ចំណែកកូនប្រុសគាត់ ៣ នាក់ ទៀតបានរៀបការ បន្ទាប់មកពួកគេបានបែកគ្រួសារទៅរស់នៅជាមួយប្រពន្ធរបស់គេអស់ហើយ។ បន្ទាប់ពីកូនៗរៀបការរួច គាត់បានបែងចែកដីដាំដុះទៅដល់ពួកគេទាំង ៣ នាក់ ចំនួន ២ ហ.ត ដូច្នេះលោកពូនៅសល់ដីដាំដុះត្រឹម ០.៥ហ.ត ប៉ុណ្ណោះ។ ក្នុងអំឡុងពេលនោះដែរ លំនៅដ្ឋានរបស់គាត់ហ៊ុំព័ទ្ធជុំវិញដោយវាលស្រែ ហើយនៅរដូវប្រាំងជុំវិញលំនៅដ្ឋាននេះ មានសភាពក្រៀមក្រោះដោយសារតែកង្វះនូវប្រភពទឹកពេញមួយរដូវប្រាំង។

ចំពោះការសិក្សា លោកពូបានរៀនត្រឹមថ្នាក់ទី ១០ ពីសង្គម ស្មើថ្នាក់ទី ៣ សព្វថ្ងៃ ដោយសារតែជីវភាពគ្រួសារមិនអំណោយផល។ ហើយចាប់តាំងពីពេលនោះមករហូតមកទល់សព្វថ្ងៃ មានរយៈពេលជាង ៤ ទសវត្សរ៍ ដែលរូបគាត់មិនបានកាន់ប៊ិចយកមកសរសេរ (ភ្លេចតួអក្សរ) និងសៀវភៅក៏មិនសូវបានអាន (អានយឺត)។

នៅអំឡុងឆ្នាំ ២០០០-២០០២ គ្រួសាររបស់គាត់ជួបនូវភាពលំបាកខ្លាំង ដោយសារតែគាត់ពឹងផ្អែកទាំងស្រុងលើការងារកសិកម្មតាមទំលាប់ចាស់បុរាណ ហើយបើឆ្នាំណាធម្មជាតិអំណោយផលល្អ គាត់អាចលក់ផលដំណាំ ជាពិសេសផលស្រូវបានខ្លះសំរាប់ទូទាត់ការចំណាយក្នុងផលិតកម្ម និងចំណាយក្នុងគ្រួសារ តែបើឆ្នាំណាធម្មជាតិមិនអំណោយផលទេ ពេលនោះគាត់មិនមានផលដំណាំលក់សំរាប់ដោះស្រាយអ្វីដែលបានចំណាយរួចនោះឡើយ។ នេះជាបញ្ហា និងឧបសគ្គដែលគាត់ប្រឈមមុខយ៉ាងខ្លាំង ពីព្រោះក្នុងមួយឆ្នាំៗគាត់ចំណាយអស់ប្រមាណជា ៥៥៥ ០០០ រៀល ស្មើនឹង ១៤៦ ដុល្លា ទៅលើការទិញ ជី និងថ្នាំពុលគីមី ជួលកំលាំងពលកម្មពីខាងក្រៅ (ភ្ជួរ ដក និងស្ទូង) និងពូជដំណាំជាដើម។ ជាក់ស្តែងដូចជាការធ្វើស្រូវ ក្នុងមួយឆ្នាំគាត់ទទួលបានផលជាមធ្យមត្រឹម ១៧៥០ គ.ក្រ នៅលើដីទំហំ ២ ហ.ត (ប្រមាណជា ០.៨៧ ត/ហ.ត) និង ចំណូលពីការដាំបន្លែនៅចំការទទួលបានប្រមាណជា ៥០០ ០០០ រៀល ស្មើនឹង ១៣០ ដុល្លា។ រៀងរាល់ថ្ងៃ លោកពូមិនដែលមានពេលនៅធ្វើកិច្ចការផ្ទះទេ និងលើសពីនោះ គាត់មិនដែលមានឱកាសបានចេញទៅក្រៅដើម្បីរៀនសូត្រ និងដើរកំសាន្តឡើយ (ដូចកង្កែបក្នុងអណ្តូង) ពីព្រោះបន្ទាប់ពីការដាំដុះស្រូវរួចគាត់ត្រូវទៅដាំដំណាំនៅមាត់ស្ទឹងស្លាគូបន្តទៀត ដែលមានចំងាយពីផ្ទះប្រមាណ ២ គ.ម។ ក្នុងពេលជាមួយគ្នានោះដែរ គាត់

សង្កេតឃើញថាគាត់ និងប្រពន្ធឧស្សាហ៍ឈឺ ញឹកញាប់ណាស់ក្នុងមួយឆ្នាំៗ ដូចជា ផ្តាសាយ ក្អក វិលមុខជាដើម នេះដោយសារតែគាត់ហូបពុំបាន គ្រប់គ្រាន់ ( កង្វះ សារធាតុចិញ្ចឹម) ធ្វើការហួសកំលាំង និងការប្រើបាស់ថ្នាំកសិកម្មពុំបានត្រឹមត្រូវ ។

កត្តាទាំងអស់ខាងលើនេះហើយ ដែលជំរុញចិត្តរបស់លោកពូអោយធ្វើការសហការជាមួយ **សេដាក** នៅពេលដែល សេដាកបានចុះមកផ្សព្វផ្សាយអំពីសកម្មភាពការងារនៅក្នុងភូមិរបស់គាត់ដំបូង ។ លោកពូបានសហការជាមួយ សេដាក ចាប់តាំងពី ខែកក្កដា ឆ្នាំ ២០០៣ រហូតមកទល់សព្វថ្ងៃ តាមរយៈគំរោង SRL_EED ។ តែដោយគំរោង SRL_EED បានបញ្ចប់បេសកកម្មរបស់ខ្លួននៅក្នុងខែធ្នូ ឆ្នាំ ២០០៧ ដូច្នេះលោកពូក៏បានបន្តការសហការជាមួយគំរោងថ្មីមួយទៀត ឈ្មោះគំរោង PRS_EU ចាប់តាំងពីខែមករា ឆ្នាំ ២០០៨ រហូតទៅទល់នឹងចុងឆ្នាំ ២០១០ ។ គំរោង PRS_EU ក៏ជាគំរោងមួយក្នុងចំណោមគំរោងអភិវឌ្ឍន៍មូលដ្ឋានជាច្រើនទៀតរបស់អង្គការ សេដាក ដែលបាននឹងកំពុងបំពេញបេសកកម្ម របស់ខ្លួននៅភូមិចំនួន ២៦០ ក្នុងខេត្តតាកែវ និងកំពង់ស្ពឺ ។

បន្ទាប់ពីបានសហការជាមួយ សេដាក អស់រយៈពេល ៦៦ ខែ កន្លងមក ការងារដែលគាត់បានអនុវត្ត និងលទ្ធផល ដែលគាត់ទទួលបានមានបង្ហាញជូនដូចខាងក្រោម :

- ចាប់ផ្តើមដំបូងដោយការទទួលយកបច្ចេកទេស ប.វ.ស ដែលគំរោងបានផ្សព្វផ្សាយយកទៅអនុវត្តន៏នៅលើផ្ទៃដីទំហំ ៥ អារ ដោយទទួលបានផលសរុបចំនួន ៣០០ គ.ក្រ ស្មើនឹង ៦ ត/ហ.ត ដោយពុំចាំបាច់ប្រើជីគីមី និងជួលកំលាំងពលកម្មពីខាងក្រៅសំរាប់ ដក-ស្ទូង ដូចមុនឡើយ ។ ដោយបានឃើញថា ការធ្វើតាម ប.វ.ស មានការចំណាយតិច តែទទួលបានផលខ្ពស់ នៅឆ្នាំ ២០០៤ គាត់បានពង្រីកផ្ទៃដី ប.វ.ស រហូតដល់ ២០អារ ហើយចាប់តាំងពីឆ្នាំ ២០០៥ រហូតមកទល់ឆ្នាំ ២០០៨ គាត់បានធ្វើតាម ប.វ.ស នៅលើផ្ទៃដីទាំងអស់ដែលគាត់មាន ។ ឆ្លងតាមរយៈបទពិសោធន៏ពីមួយឆ្នាំទៅមួយឆ្នាំ គាត់បានសង្កេតឃើញថាផលស្រូវរបស់គាត់បានកើនឡើងជាប់ជារៀងរាល់ឆ្នាំ ( សូមមើលតារាងទី ១) ។

**តារាងទី ១ : ព័ត៌មានអំពីការវិវត្តន៏នៃផលស្រូវបន្ទាប់ពីបានសហការជាមួយគំរោង**

| ពិពណ៌នា | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|
| ផ្ទៃដីធ្វើស្រែសរុប ( អារ) | ២០០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |
| ផ្ទៃដីធ្វើ ប.វ.ស ( អារ) | ៥ | ២០ | ៣០ | ៣០ | ៣០ | ៣០ |
| ផលស្រូវសរុប ( គ.ក្រ) | ១៥៦០ | ១០០០ | ១៤៤០ | ១៥៦០ | ១៩៥០ | ២១០០ |
| ផលស្រូវ ប.វ.ស ( គ.ក្រ) | ៣០០ | ៨៥០ | ១៤៤០ | ១៥៦០ | ១៩៥០ | ២១០០ |
| **ទិន្នផលប.វ.ស (ត/ហ.ត)** | **៦.០០** | **៤.២៥** | **៤.៨០** | **៥.២០** | **៦.៥០** | **៧.០០** |

- ដោយទទួលបានការណែនាំ និងជំរុញពីបុគ្គលិកគំរោង នៅដើមឆ្នាំ ២០០៤ គាត់បានរៀបចំកសិដ្ឋានពហុប្រយោជន៍មួយនៅលើផ្ទៃដីទំហំ ២០ អារ ដែលវាជាកន្លែងសំរាប់ធ្វើស្រែរបស់គាត់តាំងពីដើមមក។ ចាប់តាំងពីឆ្នាំ ២០០៤ រហូតមកទល់សព្វថ្ងៃនេះ កសិដ្ឋានរបស់គាត់ត្រូវបានកែលំអជាប់ជារៀងរាល់ឆ្នាំ លើសពីនេះទៅទៀត លោកពូបានខិតខំស្រាវជ្រាវ និងរុករកនូវបច្ចេកទេសថ្មីៗទាក់ទងការងារដាំដុះបន្ថែមទៀត។ បច្ចុប្បន្នកសិដ្ឋានរបស់គាត់មានស្រះទឹក មានប្រព័ន្ធប្រលាយមេ ព័ទ្ធជុំវិញកសិដ្ឋាន មានប្រព័ន្ធប្រលាយរង តភ្ជាប់ទៅជុំវិញដីស្រែ មានកន្លែងសំរាប់ចិញ្ចឹមមាន់ មានកន្លែងសំរាប់ដាំដំណាំបន្លែ គ្រឿងទេស ឈើហូបផ្លែ ឈើពហុប្រយោជន៍ រុក្ខជាតិចំណីសត្វ កន្លែងផលិតជីធម្មជាតិ (កំប៉ុស្ត ជីទឹក និងថ្នាំពុលធម្មជាតិ) និងកន្លែង សំរាប់បណ្តុះកូនឈើ និងពូជដំណាំ និងមានត្រីដែលដាក់ចិញ្ចឹម និងត្រីធម្មជាតិ ហើយលើសពីនោះទៅទៀត កសិដ្ឋានរបស់គាត់មានពណ៌បៃតងពេញមួយឆ្នាំ និងមានប្រភពទឹកសំរាប់ប្រើប្រាស់ពេញមួយឆ្នាំផងដែរ។ នៅប៉ុន្មានឆ្នាំចុងក្រោយ គាត់សង្កេតឃើញថា ក្នុងកសិដ្ឋានរបស់គាត់ យើងចង់ធ្វើអ្វី និងដាំអ្វីក៏កើត ដោយសារជីជាតិដី និងមានការជួយគ្នាទៅវិញទៅមករបស់ដំណាំ។ បន្ទាប់ពីមានកសិដ្ឋាននៅជាប់ផ្ទះ ភាពនឿយហត់ និងការលំបាកដែលពីមុនបានជួប ឥឡូវត្រូវបានកាត់បន្ថយទាំងស្រុង ហើយគាត់មានពេលវេលា ធ្វើកិច្ចការផ្ទះ មានពេលវេលាចេញទៅក្រៅ ដើម្បីចូលរួមរៀនសូត្រ និងចូលរួមទស្សនៈកិច្ចសិក្សានៅក្នុងស្រុក និងក្រៅស្រុក។ ចំពោះប្រាក់ចំណូលដែលគាត់ទទួលបានពីកសិដ្ឋានចំរុះមានបង្ហាញជូនក្នុងតារាងទី ២។

**តារាងទី ២ : ព័ត៌មានអំពីប្រាក់ចំណូលដែលទទួលបានពីកសិដ្ឋានពហុប្រយោជន៍**

| ប្រភេទចំណូលសំខាន់ៗ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ចំណូលពីបន្លែ (រៀល) | ២០០ ០០០ | ៣០០ ០០០ | ៣០០ ០០០ | ៣៥០ ០០០ | ៣០០ ០០០ |
| ចំណូលពីឈើហូបផ្លែ (រៀល) | ១០០ ០០០ | ១៤០ ០០០ | ២៥០ ០០០ | ២០០ ០០០ | ៣០០ ០០០ |
| ចំណូលពីលក់ត្រី (រៀល) | ១៥០ ០០០ | ១៥០ ០០០ | ៣០០ ០០០ | ២៥០ ០០០ | ១៥០ ០០០ |
| ចំណូលពីលក់មាន់ (រៀល) | ១២០ ០០០ | ២៤០ ០០០ | ៣០០ ០០០ | ២៥០ ០០០ | ៤៥០ ០០០ |
| **សរុបចំណូលប្រចាំឆ្នាំ** | **៥៧០ ០០០** | **៨៣០ ០០០** | **១ ១១៥ ០០០** | **១ ០៥០ ០០០** | **១ ២០០ ០០០** |

## ផែនការសំរាប់ឆ្នាំខាងមុខ

- កែលំអកសិដ្ឋានបន្តទៀត តាមរយៈការស្តារប្រលាយ និងពង្រីកស្រះទឹក
- បង្កើន និងកែលំអការចិញ្ចឹមមាន់ តាមរយៈការបង្កើនចំនួនមេមាន់អោយបាន ១២ ក្បាល និងរៀបចំទ្រុងសំរាប់មាន់ដេក មាន់ពង និងទ្រុងបំបែកកូនអោយបានល្អ
- បន្តរុករក និងស្រាវជ្រាវនូវគំនិតថ្មីៗបន្ថែមទៀត
- កែលំអ ការបន្សុទ្ធពូជស្រូវអោយបានជាប់រៀងរាល់ឆ្នាំ និងពង្រីកការផលិតពូជនៅលើផ្ទៃដីទំហំ ២០ អារ

- រៀបចំរោង ១ សំរាប់ធ្វើជាកន្លែងជួបជុំរបស់កសិករក្នុងភូមិ និងសំរាប់ភ្ញៀវដែលមករៀនសូត្រជាមួយ តែថវិការបស់គាត់នៅមានកំរិតមិនដឹងថាអាចមានលទ្ធភាពក្នុងការសាងសង់ឬអត់ ។

**<u>ចំណាប់អារម្មណ៍</u>**

- ជីវភាពគ្រួសារមានភាពប្រសើរឡើងគួរអោយកត់សំគាល់ ដូចជាប្រាក់ចំណូលកើនឡើងច្រើន ហើយលើសពីនោះទៅទៀត គាត់មានបន្លែ ត្រី សាច់ហូបគ្រប់គ្រាន់ពេញមួយឆ្នាំ ដោយពុំចាំបាច់ទៅទិញពីផ្សារដូចមុន ។
- ពុំសូវព្រួយបារម្ភណ៍ និងខ្វល់ខ្វាយដូចកាលមុន ដោយសារពុំមានការចំណាយអ្វីអោយធំដុំ ហើយភាពប្រថុយប្រថានក៏មិនមានដែរ ។
- មានការរាប់អាន និងទទួលស្គាល់ពីអ្នកខាងក្នុង និងក្រៅភូមិច្រើន ជាពិសេសអជ្ញាធរមូលដ្ឋាន
- កើនឡើងនូវចំណេះដឹង និងបទពិសោធន៍ (សរសេរ អាន និយាយ និងការធ្វើកសិកម្ម) ដែលពីមុនស្ទើតែមិនមានអ្វីនៅក្នុងខ្លួនទាល់តែសោះ សូម្បីតែនិយាយជាសាធារណៈក៏មិនចេះនិយាយផង
- ធូរកំលាំងពលកម្មជាងមុន លើសពីនោះភរិយារបស់គាត់ដែលនៅអង្គុយក្បែរនោះក៏បានបញ្ជាក់បន្ថែមទៀតថាគាត់ ឥឡូវមានពេលនៅផ្ទះទាំងរាល់ថ្ងៃ បានធូរកំលាំង និងស្រណុកជាងមុនច្រើន ។











